# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ទេព សារុន ភេទប្រុស អាយុ៧០ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ កងចល័ត
## ស្រុកកំណើតនៅភូមិខ្វាន់ ឃុំខ្វាន់ ស្រុករវៀង ខេត្តព្រះវិហារ
## រស់នៅភូមិបន្ទាយចាស់ ឃុំព្រះប្រឡាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០០:៥៥:៥៨
## ២២ទំព័រ

ដានីៈ អ៊ីចឹងអ៊ំដឹងប្អូនខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ?

សារុនៈ ឈ្មោះខ្ញុំ?

ដានីៈ បាទ!

សារុនៈ ខ្ញុំឈ្មោះ ទេព សារុន។

ដានីៈ ទេព សារុន?

សារុនៈ បាទ!

ដានីៈ អ៊ំមានឈ្មោះអីក្រៅទៀតទេ?

សារុនៈ មាន ចាន់ ពើន។

ដានីៈ ឈ្មោះ ចាន់ ពើន?

សារុនៈ បាទ!

ដានីៈ ម៉េចបានអ៊ំមានឈ្មោះពីរអ៊ីចឹង?

សារុនៈ ខ្ញុំពីមុនកាលនៅដីថៃឈ្មោះ ចាន់ ពើន។

ដានីៈ កាលពីជំនាន់។

សារុនៈ ជំនាន់ខ្មែរក្រហម។

ដានីៈ អ៊ំ! ជំនាន់៣ឆ្នាំ?

សារុនៈ បាទ! កាលខ្ញុំនៅដីថៃ ចាន់ ពើន ឈ្មោះពីកំណើត។

ដានីៈ ពីកំណើតមកឈ្មោះ ចាន់ ពើន ដល់ក្រោយមកដាក់ទេព សារុន វិញ?

សារុនៈ ទេព សារុន វិញ។

ដានីៈ ដូរឆ្នាំណាទៅឈ្មោះ ទេព សារុន?

សារុនៈ ដូរត្រឹម២០០៣។

ដានី៖ អ៊ុំសព្វថ្ងៃអាយុប៉ុន្មានហើយ?

សារុន៖ ខ្ញុំ៧០ហើយ ។

ដានី៖ អាយុច្រើនដែលហើយ?

សារុន៖ បាទ!

ដានី៖ អ៊ុំស្រីគាត់ឈ្មោះអីដែរ?

សារុន៖ ឈ្មោះ ចាន់ គឿន ។

ដានី៖ គាត់ជាប់សាច់ញាតិអីអ៊ីដែរ?

សារុន៖ អត់សាច់ញាតិទេ តែនាមត្រកូលដូចគ្នា អីចឹងបានខ្ញុំកែមកដាក់ទេព សារុន វិញ ។

ដានី៖ អ៊ុំស្រីអាយុប៉ុន្មានដែរឥឡូវ?

សារុន៖ អាយុ៥៥ហើយ ។

ដានី៖ អ៊ុំមានកូនចៅប៉ុន្មាននាក់ដែរ?

សារុន៖ កូន៤ ។

ដានី៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅអ៊ុំ?

សារុន៖ ប្រុសទាំងអស់ ។

ដានី៖ ពួកគាត់ធំៗមានគ្រួសារអស់ហើយ?

សារុន៖ មានអស់ហើយ នៅសល់មួយនៅជាមួយខ្ញុំ ។

ដានី៖ សល់មួយគាត់នៅរៀន ឬក៏ឈប់ហើយ?

សារុន៖ នៅរៀន ។

ដានី៖ គាត់រៀនដល់ណាហើយ?

សារុន៖ រៀនថ្នាក់ទី១១ ។

ដានី៖ អ៊ុំគិតថាចង់ឲ្យកូនរៀនដល់ណាដែរ? កូនពៅមួយ?

សារុន៖ កូនពៅខ្ញុំចេះថា បើកូនវាខំប្រឹងចេះតែឲ្យរៀនបន្តទៅទៀត ។

ដានី៖ ចង់ឲ្យរៀនបន្តទៀតបើកូនគាត់រៀនកើត ចេះតែទៅមុខចេះតែបញ្ជូន ។ ចង់ឲ្យរៀនតនៅភ្នំពេញអីទៀត ឬទៅណា?

សារុន៖ បើថាចប់នៅក្នុងខេត្តនេះហើយ ចង់ឲ្យបន្តទៅដល់ភ្នំពេញ ។

ដានី៖ ចង់ឲ្យរៀនជំនាញខាងអីដែរ?

សារុន៖ ខ្ញុំចង់ឲ្យរៀនជំនាញខាងពេទ្យ ។

ដានី៖ ចាស់ៗពីដើមចូលចិត្តពេទ្យ?

សារុនៈ បាទ!

ដានីៈ អ៊ំភូមិនេះគេហៅភូមិ?

សារុនៈ បន្ទាយចាស់ ។

ដានីៈ ភូមិបន្ទាយចាស់ ម៉េចបានគេដាក់ឈ្មោះបន្ទាយចាស់អីចឹង?

សារុនៈ កាលចុះមកហ្នឹងមានបន្ទាយយួនពីមុនមក បន្ទាយចាស់កាលយួនមកហ្នឹង បន្ទាយចាស់គេនៅខាងក្រោយនេះ មកឃើញបន្ទាយចាស់ដែលគេនៅ ក៏ដាក់ឈ្មោះភូមិបន្ទាយចាស់ ។

ដានីៈ អីចឹងបន្ទាយចាស់នេះដោយសារកាលពីមុនជាបន្ទាយរបស់យួន?

សារុនៈ របស់យួន ។

ដានីៈ ដល់យើងចុះមក យើងឃើញបន្ទាយហ្នឹង ក៏ដាក់ឈ្មោះបន្ទាយចាស់ទៅ?

សារុនៈ ដាក់ឈ្មោះបន្ទាយចាស់ទៅ ។

ដានីៈ ឃុំព្រះប្រឡាយ?

សារុនៈ ព្រះប្រឡាយ ។

ដានីៈ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ?

សារុនៈ បាទ ។

ដានីៈ អ៊ំស្រុកកំណើតអ៊ំនៅណាដែរ?

សារុនៈ ខ្ញុំនៅភូមិខ្នាន់ ។

ដានីៈ នៅក្នុងឃុំ ស្រុកអីទៅ?

សារុនៈ ស្រុករវៀង ។

ដានីៈ ខាងព្រះវិហារ?

សារុនៈ បាទ! ខាងព្រះវិហារ ។

ដានីៈ ឃុំអីគេ នៅខាងខ្នាន់?

សារុនៈ ពីដើមឃុំបាក់ក្តោង កាលខ្ញុំនៅ តែឥឡូវមិនដឹងគេប្រែម៉េចទេ ។

ដានីៈ ជំនាន់អ៊ំគេហៅបាក់ក្តោង?

សារុនៈ បាក់ក្តោង ។

ដានីៈ អ៊ំធ្លាប់ទៅលេងស្រុកវិញដែលអត់ទេ?

សារុនៈ ទៅ ។

ដានីៈ ទៅលេងដែរ?

សារុនៈ បាទ! ទៅលេង ។

ដានីៈ អ៊ំមានបងប្អូនប៉ុន្មាននាក់ទៅ?

សារុនៈ បងប្អូននៅអ៊ីភូមិនៅ២នាក់ ។

ដានីៈ ទាំងអស់ប៉ុន្មាននាក់?

សារុនៈ ទាំងអស់៤ទាំងខ្ញុំ ។

ដានីៈ ទាំងអស់៤នាក់ដែរ! ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

សារុនៈ ប្រុស៣ ស្រី១ ។

ដានីៈ ស្រដៀងអ៊ីដែរ?

សារុនៈ បាទ!

ដានីៈ តែអ៊ំប្រុសទាំងអស់?

សារុនៈ បាទ!

ដានីៈ ហើយអ៊ំកាលពីជំនាន់នៅក្មេងៗ រៀនសូត្របានច្រើនដែរ?

សារុនៈ ខ្ញុំមិនដែលបានរៀនទេ ខ្ញុំបួស ។

ដានីៈ អ៊ំបួសបានច្រើនវស្សាដែរ?

សារុនៈ ខ្ញុំបាន៤-៥វស្សា ។

ដានីៈ បានពេញភិកអីដែរ?

សារុនៈ បាទ!

ដានីៈ ដល់ពេលសឹកមកវិញយើង?

សារុនៈ មានគ្រួសារ ។

ដានីៈ តាំងពីជំនាន់ណាទៅមានគ្រួសារ?

សារុនៈ គ្រួសារទើបតែយកទេខ្ញុំ ដល់សឹកមកទៅវាមានស្រុកទេសវា កាលនោះរដ្ឋប្រហារ វាបាក់បែកគ្នាទៅ ។

ដានីៈ រដ្ឋប្រហារឆ្នាំ៧០?

សារុនៈ ៧០ ។

ដានីៈ ដល់ពេលរដ្ឋប្រហារហើយអ៊ំយ៉ាងម៉េចទៀតទៅ?

សារុនៈ រដ្ឋប្រហារខ្ញុំនៅធ្វើស្រែចំការធម្មតា ។

ដានីៈ ធ្វើស្រែចំការដល់ឆ្នាំណាទៅ?

សារុនៈ ធ្វើចេះតែធ្វើ ដល់ឆ្នាំ៨៨ ។

ដានីៈ ចុះអ៊ំកាលពីឆ្នាំ៧៥-៧៩ កាលជំនាន់យើង?

សារុនៈ នៅនឹងភូមិហ្នឹងដែរ ។

ដានីៈ កាលហ្នឹងជំនាន់ហ្នឹងយ៉ាងម៉េចខ្លះដែលទៅ?

សារុនៈ នៅក្នុងសហករណ៍ហូបបាយរួម ។

ដានីៈ នៅក្នុងភូមិធ្វើសហករណ៍?

សារុនៈ បាទ!

ដានីៈ កាលនៅហ្នឹងនៅក្នុងស្រុករវៀងដែរ?

សារុនៈ ស្រុករវៀង ។

ដានីៈ តំបន់ប៉ុន្មានកាលហ្នឹង?

សារុនៈ កាលនោះ?

ដានីៈ បាទ!

សារុនៈ កាលជំនាន់ហ្នឹង ក្រោយមកគេដាក់តំបន់១០៣ ។

ដានីៈ ដាក់តំបន់១០៣វិញ?

សារុនៈ បាទ!

ដានីៈ អ៊ំនៅក្នុងសហករណ៍រហូត?

សារុនៈ បាទ!

ដានីៈ កាលហ្នឹងការងាររយ៉ាងម៉េចដែរ កាលនៅក្នុងសហករណ៍អ៊ំ?

សារុនៈ ការងាររយ៉ាប់ហើយហូបមិនគ្រប់ទេ កាលនោះហូបបបរ ។

ដានីៈ គេឲ្យយើងនៅក្នុងស្រុកភូមិកំណើតយើងដែរ? ឬគេជម្លៀសទៅណា?

សារុនៈ មិនដែលជម្លៀសទៅណាទេ ខ្ញុំនៅភូមិកំណើតរហូត ។

ដានីៈ អ៊ំដល់ពេលយើងបែកឆ្នាំ៧៩ អ៊ំធ្វើអីទៅពេលដែលយួនចូលឆ្នាំ៧៩?

សារុនៈ ៧៩ខ្ញុំក៏នៅក្នុងភូមិដែរ ។

ដានីៈ ឆ្នាំ៧៩អ៊ំនៅភូមិដែរ?

សារុនៈ បាទ!

ដានីៈ យ៉ាងម៉េចដែលអ៊ំអាចរៀបរាប់កន្លែងហ្នឹងតិច? អ៊ំធ្វើអីទៅកាលឆ្នាំ៧៩យួនចូលភូមិ?

សារុនៈ អត់មានធ្វើអីទេ ។ នៅធ្វើស្រែចំការ តែកាលនោះវាប្រែប្រួល មិនដូចយើងពីសង្គមទេ ប្រែប្រួលតាំងពីការហូបចុកទៅតាមរបបគេថ្មីហ្នឹង នៅសហករណ៍ហ្នឹងរហូតដល់ពេលរំដោះ ប្អូនខ្ញុំបែកពីភ្នំពេញគេរត់ទៅនៅថៃនោះ ប្អូនប្រុស ។

ដានីៈ ប្អូនប្រុសឈ្មោះ?

សារុនៈ ឈ្មោះ ឡេ ។

ដានីៈ ឈ្មោះ ឡេ ហ្នឹងប្អូនអ៊ំបង្កើត?

សារុនៈ បាទ! ស្លាប់បាត់ហើយឥឡូវ ។

ដានីៈ ប្អូនអ៊ំគាត់ពេលយួនចូលភ្នំពេញ គាត់រត់ពីភ្នំពេញមកដងរែកយើង?

សារុនៈ បាទ! នៅខាងដងរែក ។

ដានីៈ ដល់ពេលយ៉ាងម៉េចទៅអ៊ំបាន?

សារុនៈ កាលនោះបងប្អូនចេះតែមកផ្ទះ គេហៅថាគេតស៊ូទៀតកាលនោះ ដល់ទៅគេយកខ្ញុំទៅជាមួយគេដីថៃ ។

ដានីៈ ឆ្នាំទៅអ៊ំហ្នឹង?

សារុនៈ ឆ្នាំ៨៥ ។

ដានីៈ ឆ្នាំ៨៥ ហើយ?

សារុនៈ ឆ្នាំ៨៥ ហើយ ។

ដានីៈ គាត់ទៅដល់ស្រុកកំណើត?

សារុនៈ បាទ?

ដានីៈ ប្អូនអ៊ំឈ្មោះឡេ គាត់ទៅយកអ៊ំពីស្រុកកំណើត?

សារុនៈ បាទ! ទៅយកពីរវៀង ។

ដានីៈ ដល់ពេលកាលហ្នឹងអ៊ំមកទាំងគ្រួសារទាំងអស់ ឬអ៊ំមកម្នាក់ឯង?

សារុនៈ ទៅតែឯងទេ គ្រួសារយកក្រោយ ។

ដានីៈ គ្រួសារអ៊ំមុននៅស្រុកកំណើត?

សារុនៈ បាទ!

ដានីៈ កូន៤នាក់នេះ កូនឥឡូវ ឬទាំងអស់ ទាំងនៅស្រុកកំណើត?

សារុនៈ កូនទាំងអស់៤ គ្រួសារនេះខ្ញុំយកកាលនៅដីថៃទេ ។

ដានីៈ អីចឹងពេលដែលប្អូនអ៊ំទៅយកពីរវៀងមក អ៊ំទៅនៅណាដំបូង?

សារុនៈ នៅគេហៅជំរំ១០០៣ ។

ដានីៈ កន្លែងជំរំ១០០៣ កាលហ្នឹងគេហៅកន្លែងអី? កាលហ្នឹងយើងនៅដីថៃ?

សារុនៈ ក្នុងដីថៃ ។

ដានីៈ គេហៅអីទៅនៅកន្លែងហ្នឹង?

សារុនៈ គេហៅ១០០៣ ។

ដានី៖ តែ១០០៣នៅកន្លែងដាំ, អូរម្ទូ, អូរត្រាវ?

សារុន៖ នៅ១០០៣ក្បែរអូរត្រាវ ទន្ទឹមគ្នា ។

ដានី៖ កាលហ្នឹងអ៊ំធ្វើអីទៅ?

សារុន៖ កាលនោះ?

ដានី៖ បាទ!

សារុន៖ ខ្ញុំនៅ១០០៣គ្រប់គ្រងមីង១ទទួលអំណោយកាកបាទ ។

ដានី៖ គ្រប់គ្រងមេ១?

សារុន៖ គ្រប់គ្រងប្រពន្ធគ្រួសារកងទ័ព ទាំងកុមារ ទាំងស្ត្រីគ្រួសារកងទ័ពហ្នឹងឯង ។

ដានី៖ អ៊ំគ្រប់គ្រងគ្រួសារកងទ័ព នៅក្នុងកងពលណាទៅ?

សារុន៖ កងពល៦១៦ ។

ដានី៖ កាលហ្នឹងប្អូនអ៊ំតួនាទីគាត់ធ្វើអីទៅ?

សារុន៖ រងកងពល ។

ដានី៖ កងពល៦១៦ ហើយប្រធានពីណាគេ?

សារុន៖ ប្រធានឈ្មោះតាញ៉ែន១ ។

ដានី៖ តាញ៉ែន សព្វថ្ងៃគាត់នៅសៀមរាប?

សារុន៖ បាទ!

ដានី៖ ហើយប្អូនអ៊ំឈ្មោះឡេ គាត់រង? អនុរបស់តាញ៉ែន?

សារុន៖ បាទ! មិនដឹងម៉េចទេ គេទាស់ទែងគ្នាគេ របៀបដណ្តើមនាទីគ្នាគេលួចបាញ់ប្អូនខ្ញុំទៅ ។

ដានី៖ គេលួចបាញ់ឆ្នាំណាទៅ?

សារុន៖ ឆ្នាំ៨៨ ។

ដានី៖ យ៉ាងម៉េចបានជាគេលួចបាញ់ប្អូនអ៊ំ?

សារុន៖ ខ្ញុំក្តាប់វាមិនបានទេ ព្រោះកន្លងមកហៅថាគាត់រង តែតាមខ្ញុំក្តាប់បានប្រហែលមេកងពល អាចបាញ់ របៀបប្អូនខ្ញុំឈ្លាសវៃ ហើយមេខ្លាចយើងឡើងខ្ពស់ជាងគេ គេបង្ហើយចោល ។

ដានី៖ គេលួចបាញ់គាត់នៅណាទៅ?

សារុន៖ នៅ៤០ ។

ដានី៖ នៅកន្លែងប្រេក៤០?

សារុន៖ បាទ!

ដានី៖ ពេលហ្នឹងគាត់កំពុងតែធ្វើអីបានគេលួចបាញ់គាត់?

សារុនៈ ប្រពន្ធសំរាល ក៏សុំច្បាប់គេមកថែប្រពន្ធនៅផ្ទះ ប្រពន្ធដេកភ្លើងបាន២-៣ថ្ងៃ វាចេះកាល នៅប្រពន្ធនៅម្នាក់ឯងផង អត់មានក្មេងនៅជាមួយទេ យើងមកផ្ទះ ហើយយប់ឡើងគេលួចបាញ់ បាញ់សែកន្ទះ ។

ដានីៈ បាញ់បេ?

សារុនៈ បាញ់បេ ។

ដានីៈ បាញ់ទៅត្រូវគាត់?

សារុនៈ បាញ់ហ្នឹងប្អូនខ្ញុំកំពុងចងអង្រឹងដេកនៅផ្ទះខាងក្រៅ ប្រពន្ធដេកភ្លើងនៅខាងក្នុង គេបាញ់ដំបូលតែអំបែងជះមកត្រូវ កូនដែលកើតមកត្រូវដូចគ្នាតែមិនស្លាប់ទេ ។

ដានីៈ កូនក៏ត្រូវ ចុះប្រពន្ធ?

សារុនៈ ប្រពន្ធក៏ត្រូវរបួស តែអំបែងវាខណ្ឌជញ្ជាំងគ្នា ប្អូនខ្ញុំចងអង្រឹងដេកខាងក្រៅ ដូច្នេះគេបាញ់ដំបូលវាបែកទៅចំផ្លាយភ្លោកនោម ។

ដានីៈ ត្រូវផ្លាយភ្លោកនោម?

សារុនៈ បាទ!

ដានីៈ តែប្រពន្ធកូនអត់អីទេ?

សារុនៈ អត់អីទេ ។

ដានីៈ ប្រពន្ធ កូនគាត់នៅណាឥឡូវ?

សារុនៈ ទៅភូមិកំណើតគេវិញ ។

ដានីៈ នៅណាទៅភូមិកំណើត?

សារុនៈ នៅពោធិ៍សាត់ ។

ដានីៈ ពេលដែលគេត្រូវ អ៊ំនៅក្នុងព្រឹត្តិការណ៍ហ្នឹងដែរ?

សារុនៈ នៅ នៅហ្នឹងដែរ ខ្ញុំផ្ទះឆ្ងាយពីគ្នាដែរ ។

ដានីៈ ផ្ទះប្រហែលជាប៉ុន្មាន?

សារុនៈ ផ្ទះប្រហែល២០០ម៉ែត្រពីគ្នា ។ គេបាញ់ខ្ញុំអត់ហ៊ានទៅទេ ខ្លាចដែរ ខ្លាចជួបកំលាំងគេបាញ់ទៅគេធ្វើបាបខ្ញុំទៀតខ្ញុំអត់ទៅទេ ប្អូនវាស្លាប់ទៅ ។

ដានីៈ ហើយអ៊ំមាននៅសេសសល់រូបថតគាត់ទេ?

សារុនៈ រូបថតមិនដែលមានទេ ។

ដានីៈ ហើយអ៊ំដឹងថាមេកងពលគេប្រណែនគាត់?

សារុនៈ បាទ!

ដានី: ប្រណែនទៅគេចង់កំចាត់គាត់ចេញ?

សារុន: បាទ!

ដានី: ហ្នឹងអ៊ំសន្និដ្ឋាន ឬក៏អាចមានភស្តុតាងអី?

សារុន: ខ្ញុំសន្និដ្ឋានទេ មិនមានភស្តុតាងអីទេ។

ដានី: មុននឹងគេបាញ់ ធ្វើឃាតគាត់ហ្នឹង គាត់មានដូចជាបញ្ហាឈ្លោះប្រកែកគ្នា ឬក៏ស្អីដែលធ្វើឲ្យអ៊ំសន្និដ្ឋានថាគាត់?

សារុន: វាឈ្លោះប្រកែកដែរ កាលហ្នឹងតាពឹម យើងនេះ គាត់ធ្វើការដល់ធ្វើការមេកងពលហ្នឹងគេហៅថាធ្វើពិធីមន្តអាគមស្អីៗគេ ក៏តាពឹម គាត់ប្រើប្អូនខ្ញុំទៅមើល ថាគេធ្វើអីបាញ់កាំភ្លើងកណ្តាលយប់ ដល់ទៅឃើញក្រុមការពារនីរសាមេកងពលគេធ្វើពិធីបន់ស្រន់គ្រូមន្តអាគមគេ ដល់ទៅគេបញ្ជាឲ្យចាប់ក្រុមការពារតាញ៉ែន ទៅដាក់គុក។ ប៉ុន្មានថ្ងៃទេ ២-៣ថ្ងៃបានគេដោះមកវិញ មកនៅកន្លែងវិញ ហើយតាពឹម គាត់ទៅសំរុះសំរួលម្តងហើយ សំរួលថាកុំឲ្យមានបញ្ហាជាមួយគ្នា អ្នកមកពីគុកកុំចេះរករឿងគ្នា មកសំរួលគ្នា ហើយអ្នកបាញ់ហ្នឹងបានប៉ុន្មានថ្ងៃគេរត់ទៅដីរំឯលិច អត់ហ៊ានទៅហ្នឹង។

ដានី: ហើយតាញ៉ែន គាត់មាននិយាយអីដែរអត់?

សារុន: អត់មាននិយាយទេ មានតែតាពឹម ទៅសំរួលកុំឲ្យប្អូនខ្ញុំរករឿងជាមួយតាញ៉ែន។

ដានី: អីចឹងមុនគេបាញ់គាត់មានឈ្លោះគ្នា រករឿងគ្នាមួយសារ?

សារុន: អត់ដែលមានរឿងអីទេ ខ្ញុំប៉ាន់មើល តែរបៀបហៅថា ប្រណែនគ្នា ហៅថាប្រកាន់បក្សពួក បាញ់ហ្នឹងមិនមែននេះទេ ក្រុមកងការពារតាញ៉ែន បាញ់។

ដានី: ក្រុមការពារតាញ៉ែន អ្នកបាញ់ទេ?

សារុន: អ្នកបាញ់។

ដានី: ពេលហ្នឹងគេមានធ្វើអីអ៊ំដែល ពេលគេសម្លាប់ប្អូនអ៊ំទៅ?

សារុន: ខ្ញុំអត់ហ៊ាននៅដែរ ខ្ញុំរត់មកនៅអង្គភាពផ្សេងទៀត នៅជាមួយតាកុសល។

ដានី: នៅជាមួយពូវ៉ាន់ កុសល វិញ?

សារុន: បាទ!

ដានី: អីចឹងឆ្នាំ៨៨គេសម្លាប់ប្អូនអ៊ំ អ៊ំចេញភ្លាមដែរ?

សារុន: បាទ! ចេញភ្លាម។ ខ្ញុំនៅបានមួយអាទិត្យដែរ ខ្ញុំថាអត់ហ៊ាននៅទេមិនទុកចិត្ត។

ដានី: ចេញមកនៅជាមួយ?

សារុន: នៅជាមួយកុសល គេហៅនៅដាំស្លាយើងនេះ កុសល កាលហ្នឹងមួយវរៈ។

ដានី៖ វិរៈរបស់ពីណាគេ?

សារុន៖ កុសល ។

ដានី៖ កាលហ្នឹងនៅជាំស្វាមួយវិរៈដែរ?

សារុន៖ បាទ! មួយវិរៈ ។

ដានី៖ កាលហ្នឹងក្នុងកងពលណា? គាត់នៅជាំស្វាហ្នឹង?

សារុន៖ វិរៈកុសល ដូចមិនចំណុះកងពលណាដែរ ដូចវិរៈគេម៉េចទេ ។

ដានី៖ វិរៈឯករាជ្យ?

សារុន៖ បាទ!

ដានី៖ វិរសេនាធំឯករាជ្យ?

សារុន៖ បាទ!

ដានី៖ អត់ទាន់ចូលជាមួយកងពល៦១២ទេ?

សារុន៖ នៅ ប្រហែលបាន១ឆ្នាំ បានតារឿន កងពល៦១២នេះគាត់ទៅនៅជាំស្វាដែរ ។

ដានី៖ ដល់ទៅជាំស្វាយ៉ាងម៉េចទៅអ៊ី?

សារុន៖ ដល់ពេលទៅជាំស្វាគេបញ្ចូលចំណុះកងពល៦១២ហ្នឹងឯង ។

ដានី៖ ដល់ពេលគាត់ទៅនៅជាំស្វាទៅគេបញ្ចូលគ្នា?

សារុន៖ បញ្ចូលកងពលតារឿន ។

ដានី៖ ហើយដល់ពេលបញ្ចូលទៅ ទៅជា៦១២ អ៊ីទទួលអីទៅកាលហ្នឹង?

សារុន៖ ខ្ញុំនៅតែទទួលគ្រប់គ្រងគ្រួសារកងទ័ពខាងក្រោយនេះឯង សំរាប់បើករបបជាមួយកាកបាទ

ដានី៖ ដល់ពេលហ្នឹងឆ្នាំ បានន័យថាអ៊ីចូលនៅក្នុងកងពល៦១២ហើយ ពេលហ្នឹងជិតចុះមកនៅក្នុងដីខ្មែរយើងនៅ?

សារុន៖ បាទ! ហើយឆ្នាំ៨៩ ចុះមកដីខ្មែរវិញ ។

ដានី៖ ឆ្នាំ៨៩ចុះមក?

សារុន៖ បាទ! មកនៅច្រកព្រះប្រឡាយនេះ ។

ដានី៖ កាលហ្នឹងម៉េចបានឆ្នាំ៨៩យើងចុះមកនៅច្រកព្រះប្រឡាយហ្នឹង?

សារុន៖ កាលនោះគឺថាវាយ៉ាប់អត់មានស្អីទីពឹង អត់មានជំនួយទេ ព្រោះខាងថៃគេមិនឲ្យនៅទេ រៀបចំចុះមករកដីខ្មែរវិញ វៀតណាមគេដកអស់ហើយនៅតែខ្មែរនិងខ្មែរទេ ។ ដីម្តុំនេះវាទូលាយដែរអត់មានកងទ័ពទេ មកនៅច្រកព្រះប្រឡាយ ។

ដានី៖ មានផ្លូវមានអី គេធ្វើផ្លូវចុះមកដែលអត់?

សារុនៈ ផ្លូវឡានចុះពីថៃមក ។

ដានីៈ ដល់ចុះមកដំណាលជាមួយអន្លង់វែងអីហ្នឹង?

សារុនៈ បាទ! ចុះដំណាលគ្នា ។

ដានីៈ ដល់ចុះមកនៅព្រះប្រឡាយ យើងចុះមកនៅជាកងពល ឬក៏យើងចាប់ផ្ដើមរៀបចំប្រជាជនរស់នៅជាភូមិ ជាឃុំហើយ?

សារុនៈ នៅជាភូមិហើយ ។

ដានីៈ ពេលមកដល់ព្រះប្រឡាយហ្នឹង?

សារុនៈ បាទ!

ដានីៈ កាលហ្នឹងយ៉ាងម៉េចទៅ កាលយើងមកនៅព្រះប្រឡាយហ្នឹង យើងរៀបចំជាភូមិ ជាឃុំ ជាស្រុកនៅ?

សារុនៈ បាទ! រៀបជាភូមិ មិនទាន់កើតស្រុកទេ គ្រាន់តែជាឃុំប៉ុណ្ណោះឯង ។

ដានីៈ ពីណាគេអ្នកមានគំនិតផ្ដួចផ្ដើមរៀបចំ?

សារុនៈ តាហឿន កងពល ។

ដានីៈ គាត់ឲ្យរៀបចំយ៉ាងម៉េចខ្លះទៅកាលហ្នឹងបើតាមអ៊ំចាំកាលហ្នឹង?

សារុនៈ រៀបចែកជាភូមិ ភូមិមួយត្រឹម៣០-៤០គ្រួសារ, ៥០-១០គ្រួសារមួយភូមិទៅ ។ ដូច្នេះ៧-៨ភូមិទៅក៏បង្កើតជាឃុំមួយទៅ ។

ដានីៈ គេហៅឃុំអីកាលហ្នឹង?

សារុនៈ ឃុំព្រះប្រឡាយនេះឯង ។

ដានីៈ ដាក់ឃុំព្រះប្រឡាយអីចឹងតែម្ដង?

សារុនៈ បាទ!

ដានីៈ កាលហ្នឹងអ៊ំទទួលជាមេឃុំនៅ?

សារុនៈ បាទ! ទទួលឃុំ ។

ដានីៈ អ៊ំទទួលឃុំតាំងពីហ្នឹងមក?

សារុនៈ បាទ! តាំងពីនោះមក ។

ដានីៈ កាលហ្នឹងអ៊ំរៀបការជាមួយអ៊ំស្រីថ្មីទៀតនៅ? អ៊ំក្រោយ?

សារុនៈ រៀបយូរតាំងពីនៅដីថៃនោះទេ ។

ដានីៈ រៀបតាំងពីនៅដីថៃ?

សារុនៈ បាទ!

ដានី: ប្អូនអ៊ំទៅយកមកឆ្នាំ៨៥ ដល់ពេលរៀបការក្រោយឆ្នាំណាទៅ?

សារុន: ឆ្នាំដូចជា៨៦ ។

ដានី: ដល់អ៊ំចុះមកនៅព្រះប្រឡាយរៀបចំបង្កើតជាឃុំ អ៊ំទទួលឃុំហើយយ៉ាងម៉េចទៀតទៅ?

សារុន: មិនទាន់ផ្ដាច់ខ្លួនទេកាលនោះ នៅឡើយ ខ្ញុំដូចកៅប៉ុន្មានទេក្មេង ។

ដានី: កាលមុននៅព្រះប្រឡាយ ហើយយ៉ាងម៉េចបានយើងផ្ទេរមកនៅនេះវិញ?

សារុន: ផ្ដាច់ខ្លួនហើយបាននាំគ្នាមកនៅ ។ ផ្ដាច់ខ្លួនចូលរដ្ឋាភិបាលហើយ រូតមកនេះ កាលនោះក៏លំបាកដែរពួកខ្ញុំមក អ្នកគេនៅជាមួយតាម៉ុក ធ្វើអុកឡុកពួកខ្ញុំដើរកាត់តាមជើងភ្នំគេកាត់បាញ់ប៉ុន្មានសារដែរ ។

ដានី: គេកាត់បាញ់?

សារុន: បាទ! យើងមកចូលរដ្ឋាភិបាលនោះ គេនៅតស៊ូ គេមកកាត់បាញ់មិនដឹងប៉ុន្មានសារ ។

ដានី: អ៊ំអ៊ីចឹងមកដល់កន្លែងព្រះប្រឡាយហើយយើងមិនទាន់ផ្ដាច់ខ្លួនទេ កាលហ្នឹងយើងមានបញ្ហាអីខ្លះទាក់ទងដូចថា ឆ្នាំ៨៩-៩០-៩១នៅមានទាហានខាងរដ្ឋាភិបាលគេមានចូលមកវ៉ៃហើយយើងមានផ្លាស់ប្ដូរទីតាំងអីយ៉ាងម៉េចទៀតទៅ?

សារុន: ផ្លាស់ប្ដូរដែរ វាវ៉ៃទៅរត់ទៅនៅហៅថាអូរស្វាយនោះ ដល់ផ្ដាច់ខ្លួនហើយចូលរដ្ឋាភិបាលហើយមកនៅទំនប់ដាច់វិញ ហើយខាងអន្លង់វែងគេទៅអីបាយតាប់ បែបខាងអន្លង់វែងបែបខាងខ្ញុំ៦១២មកនៅព្រះប្រឡាយ ទំនប់ដាច់ ។

ដានី: នេះអ៊ំនិយាយពីចុងក្រោយហើយ ពេលដែលយើងឆ្នាំ៩៨ហើយ ដែលយើងដំណាក់កាលចុងក្រោយ រដ្ឋាភិបាលវ៉ៃចូលមកហើយ ហើយអ៊ំនៅខាងទំនប់ដាច់ ពូដាន់ណា គាត់ទៅអូរបាយតាប់ តែមុនហ្នឹងដូចថាពេលដែលអ៊ំនៅព្រះប្រឡាយ មានទាហានខាងរដ្ឋាភិបាលចូលមកហើយវ៉ៃ អ៊ំផ្លាស់ទីទៅខាងនេះ ខាងនោះ មានដែលអត់?

សារុន: មានវ៉ៃម្ដងផ្លាស់ម្ដងទៅនៅអូរស្វាយ ហើយផ្ដាច់ខ្លួននៅអូរស្វាយហ្នឹងឯង ។

ដានី: អីចឹងចេញពីព្រះប្រឡាយទៅនៅអូរស្វាយ?

សារុន: បាទ!

ដានី: តែទៅនៅអូរស្វាយយើងនៅជុំគ្នាទាំងមូល ឈប់លែងមានជាឃុំ ឬនៅតែអីចឹង?

សារុន: នៅ ព្រោះនៅកាលនោះ យើងទៅនៅអូរស្វាយយើងបោះឆ្នោតអណត្តិទី១រដ្ឋាភិបាលកាលបោះឆ្នោតហ្នឹងគឺខ្ញុំធ្វើប្រធានការិយាល័យនៅនោះ ។

ដានី: នៅណាទៅ?

សារុនៈ នៅអូរស្វាយខាងឃុំព្រះប្រឡាយនេះ ខ្ញុំធ្វើប្រធានការិយាល័យបោះឆ្នោតរដ្ឋាភិបាលមុនដំបូង ។

ដានីៈ អ៊ីចឹងបោះឆ្នោតឆ្នាំ៩៨?

សារុនៈ នោះឯង ដល់បោះឆ្នោតកាលនោះមិនទាន់ស្រួលទេពួកខ្ញុំយកសន្លឹកឆ្នោតទៅគេកាត់បាញ់មិនដឹងប៉ុន្មានសារ ពួកអ្នកនៅលើអត់ទាន់ចុះមកអស់ទេ ពួកតាម៉ុកនោះ ពួកខ្ញុំបោះឆ្នោតនៅអូរស្វាយ ហើយយកសន្លឹកឆ្នោតទៅកាលនោះ ខាងយោធា ម៉ាត់ ដឺឡា គាត់មកនៅផ្លូវ ឃុំថ្លូវ ។

ដានីៈ គាត់ឈ្មោះអី?

សារុនៈ ទាហាន?

ដានីៈ បាទ! ឈ្មោះអី?

សារុនៈ ម៉ាត់ តាឡា ។

ដានីៈ ម៉ាត់ តាឡា គាត់ជនជាតិឥស្លាម?

សារុនៈ មិនដឹងស្អី ប្រហែលឥស្លាមដឹង ។

ដានីៈ ម៉ាត់ តាឡា អ៊ីចឹងតែម្តង?

សារុនៈ ម៉ាត់ តាឡា ។

ដានីៈ កន្លែងហ្នឹងពេលដែលនេះមានការិយាល័យបោះឆ្នោតមួយនៅអូរស្វាយ?

សារុនៈ នៅអូរស្វាយ ។

ដានីៈ ហើយប្រជាជននៅហ្នឹងចូលមកបោះឆ្នោតដែរ?

សារុនៈ បាទ! បោះឆ្នោតទាំងអស់ ។

ដានីៈ មានមន្ត្រីខាងសង្កេតការណ៍គេចូលមកដែលអត់ទេ?

សារុនៈ អត់មានទេ មានតែខាងសិចមកពីសៀមរាប ។

ដានីៈ ដល់ពេលខាងទាហានរដ្ឋាភិបាលក៏នៅក្បែរៗហ្នឹងដែរ?

សារុនៈ នៅហ្នឹងឯង ។

ដានីៈ កាលហ្នឹងយើងផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាលនៅ?

សារុនៈ ចូលហើយ ។

ដានីៈ ពេលនៅអូរស្វាយហ្នឹង?

សារុនៈ បាទ!

ដានីៈ ដល់អ៊ីចឹងខាងតាម៉ុក គេយ៉ាងម៉េច?

សារុនៈ ខាងតាម៉ុក គេនៅលើភ្នំ តែអត់ចូលមកវ៉ៃទេ ពួកខ្ញុំនៅធម្មតា បោះឆ្នោតធម្មតា ។ តែរៀបចំបោះឆ្នោតហើយថ្ងៃយកសន្លឹកយកទៅប្រមូលផ្តុំគ្នានៅកន្លែងសិចនៅត្រពាំងប្រាសាទ ហ្នឹងគេរៀបកំលាំងចុះមកកាត់ផ្លូវដើម្បីវ៉ៃកំទិចសន្លឹកឆ្នោត ។ កាលហ្នឹងពួកខ្ញុំអ្នករៀបចំបោះឆ្នោតស្លាប់ក្រែលដែរ ដឹកហិបឆ្នោតមកពីអន្លង់វែងមកពួកកប៉ាល់បោះ ដឹកហិបឆ្នោតមកដាក់នៅអន្លង់វែងដល់ខាងខ្ញុំត្រពាំងប្រាសាទទៅយកហិបឆ្នោតហ្នឹងមក ដល់មកខាងកំលាំងតាម៉ុក វ៉ៃកាត់ស្លាប់អស់ប៉ុន្មាននាក់ដែរ ។

ដានីៈ ស្លាប់ខាងណា?

សារុនៈ ស្លាប់ពួកខ្ញុំអ្នកទៅដឹកហិបឆ្នោត ។

ដានីៈ អ្នកទៅដឹកហិបឆ្នោតពួកតាម៉ុកវ៉ៃកាត់បាញ់ស្លាប់អស់?

សារុនៈ បាញ់ស្លាប់ឆេះអាត្រាក់មួយទៅ ។

ដានីៈ មួយទៀតខ្ញុំចង់ដឹងទាក់ទងពីបញ្ហាផ្ទៃក្នុងខ្មែរក្រហម ដូចយើងចាប់ផ្តើមបែកបាក់គ្នាហ្នឹងយ៉ាងម៉េចដែរ? ហើយចាប់បែកបាក់តាំងពីអង្កាល់? មូលហេតុអីបានបែកបាក់គ្នាដែរ?

សារុនៈ បែកបាក់ដែលអ្នកខ្លះចុះមក ហើយអ្នកនៅនោះ?

ដានីៈ បាទ! ដូចថាមុនដំបូងយើងនៅជាមួយគ្នា មានតាម៉ុក, តាសុន សេន, តាប៉ុល ពត គាត់នៅជុំគ្នាទាំងអស់ ដល់ក្រោយមកមានការសម្លាប់តាសុន សេន ហើយតាម៉ុក ហើយនិងតាប៉ុល ពត គាត់ចាប់ផ្តើមបែកកំលាំងវ៉ៃគ្នា ។ ហើយតាម៉ុក ចាប់តាប៉ុល ពត, ចាប់តា ០៥, ០៦ មេទ័ពមួយចំនួនទៀតយកទៅសម្លាប់ ហើយដាក់ឃុំឃាំង ។ មូលហេតុដំបូងមូលហេតុយ៉ាងម៉េចដែរ?

សារុនៈ មិនដឹងយ៉ាងម៉េចទេ ដល់ឃើញអត់ស្រួលបានពួកខ្ញុំបែកបាក់គ្នារត់ចុះមកចូលរដ្ឋាភិបាល មើលទៅវាអត់ស្រួល មេៗកាន់តែបាត់ទៅៗ ដល់អីចឹងមេប៉ុន្មានៗ កាលនោះវាដូចជាម្តុំតាកែវ កាលនោះគឺតាម៉ុក គាត់យកទៅដាក់ពិន័យ អ្នកដឹកនាំយើងខាងនេះ ។ ដល់ដាក់ពិន័យមើលទៅអត់ស្រួលបាននាំគ្នាយើងទៅមានចូលរដ្ឋាភិបាលវិញ ឥឡូវឈប់ទៅតាមតាម៉ុកហើយខ្ជិល ដល់ហើយនាំប្រជាពលរដ្ឋផ្តាច់ខ្លួន ។ កាលនោះផ្តាច់ខ្លួនមុនដំបូង មាស សុភា មកចុះកប៉ាល់ហោះនៅទំនប់ដាច់ មកចែកអំណោយ ។

ដានីៈ ឯកឧត្តម មាស សុភា គាត់មកដល់ ចុះកប៉ាល់បោះនៅទំនប់ដាច់ហ្នឹង?

សារុនៈ មកចែកលុយ ។

ដានីៈ មានឯកឧត្តម មាស សុភា មានពីណាទៀតខាងរដ្ឋាភិបាល?

សារុនៈ ខ្ញុំស្គាល់តែមាស សុភា ហ្នឹងមួយ ក្រៅពីហ្នឹងអត់ ។

ដានី: តែអ៊ីបញ្ហាដូចជាការស្លាប់របស់តាសុន សេន តាមអ៊ីវិញមូលហេតុអីបានការស្លាប់របស់តាសុន សេនហ្នឹង?

សារុនៈ ក្តាប់មិនបានទេ ព្រោះការងាររបស់ខាងលើ ក្តោបក្តាប់អត់បានទេ ។

ដានី: តាម៉ុក យ៉ាងម៉េចដែរ?

សារុនៈ តាម៉ុក កាលប្រជាជនផ្តាច់ខ្លួនមួយចំណែក ហៅថាបែងចែកគូសត្រូវគ្នាទៅហើយ កាលនោះ ប៉ះគ្នាអត់បានទេដូចខ្ញុំថា ។ ខាងអ្នកផ្តាច់ខ្លួនដើរចុះឡើងក៏គេកាត់វ៉ៃ កាត់បាញ់ ហៅថាជាសត្រូវជាមួយគ្នាហើយ ។

ដានី: ខាងតាម៉ុក ថាខាងត្រពាំងប្រាសាទក្បត់?

សារុនៈ បាទ!

ដានី: បើតាមទស្សនៈអ៊ីវិញថាខាងតាម៉ុក ថាខាងត្រពាំងប្រាសាទ ខាងអ៊ីក្បត់ហ្នឹងត្រឹមត្រូវដែលអត់ទេ?

សារុនៈ ថាម៉េចបើយើងក្បត់ពីគេហើយ យើងមកចូលរដ្ឋាភិបាលគេថាយើងក្បត់ហ្នឹងឯង ។

ដានី: តែមូលហេតុដែលធ្វើឲ្យយើងចូលជាមួយរដ្ឋាភិបាល មកពីមូលហេតុអី?

សារុនៈ មូលហេតុដូចខ្ញុំថាម៉ិញ មើលទៅវាគ្រោះរង្គើលខ្លាំងពេកផ្ទៃក្នុង ដល់អីចឹងម្នាក់ៗបាត់ជំនឿទៅចេះតែភ័យខ្លាចទាំងអស់ អ្នកធ្វើការងារតិចតួច តូចតាចអី ចេះតែភ័យខ្លួននាំប្រជាជនផ្តាច់ចូលរដ្ឋាភិបាលទៅ ។

ដានី: ហើយការដែលរៀបចំបោះឆ្នោតហ្នឹង កាលហ្នឹងយើងចូលជាមួយរដ្ឋាភិបាលហើយបានរៀបចំបោះឆ្នោតហ្នឹង មានកំលាំងរដ្ឋាភិបាលនៅការពារយើងដែរ ។

សារុនៈ នៅ ។

ដានី: មេបញ្ជាការឈ្មោះម៉ាត់ ។

សារុនៈ ម៉ាត់ តេឡា ។

ដានី: គាត់ឈរនៅខាងផ្លូវ?

សារុនៈ នៅផ្លូវ ។

ដានី: ហើយកំលាំងតាម៉ុក គាត់នៅលើភ្នំ?

សារុនៈ នៅលើភ្នំ ។

ដានី: ហើយកំលាំងតាម៉ុក មានឆ្មក់មកវ៉ៃកំលាំងរដ្ឋាភិបាលអត់កាលហ្នឹង?

សារុនៈ អត់ទេ គ្រាន់តែយើងដើរចុះឡើងកាត់វ៉ៃ ទាក់ទងគ្នាកាត់ទៅរកអ្នកអន្លង់វែងអត់បានទេ ៦១២នៅខាងនេះ អ្នកនោះក៏មិនដែលចេញចូលគ្នាទេ ។

ដានី: អីចឹង៦១២កាលហ្នឹងចូលជាមួយរដ្ឋាភិបាល ឬចូលទៅជាមួយតាម៉ុក?

សារុន: ចូលរដ្ឋាភិបាល ៦១២ ។

ដានី: តាហឿន គាត់ចូលជាមួយរដ្ឋាភិបាលដែរ?

សារុន: តាហឿន ហ្នឹងគាត់នាំមកចូលរដ្ឋាភិបាល ។ តាហឿន គាត់អត់ទុកចិត្តដែរ អ្នកធំៗខាងលើ ចេះតែរបេះរបោចទៅ តាហឿន គាត់អត់ទុកចិត្ត ។

ដានី: អីកាលហ្នឹងយើងមិនទាន់បានបោះឆ្នោត យកហិបទៅវិញគេស្មាក់វៃ ឬយើងគ្រាន់តែទៅ ទទួលយកហិបឆ្នោតគេស្មាក់បាញ់?

សារុន: ខាងខ្ញុំបានបោះហើយ មានសន្លឹកឆ្នោតនៅក្នុងហិបហើយ ។

ដានី: ដល់ពេលសន្លឹកឆ្នោតបានបញ្ជូនទៅដល់ណាដែរ?

សារុន: សន្លឹកឆ្នោតបញ្ជូនទៅត្រពាំងប្រាសាទ តែខាងសៀមរាបគេចុះមកយក កប៉ាល់ហោះចុះមក យក ។

ដានី: មកយកបានទៅដែលអត់?

សារុន: បាន ។

ដានី: ដល់ពេលណាទៅដែលយើងចេញពីអូរស្មាច់ យើងត្រឡប់មកនៅនេះវិញ?

សារុន: ចេញពីអូរស្មាច់គឺការបំបែក បង្កើតជាឃុំ ជាភូមិ ។ ខាងនេះគេហៅថាឃុំព្រះប្រឡាយ មានចែកឃុំព្រះប្រឡាយ, ឃុំទំនប់ដាច់, ឃុំអូរស្មាច់, ឃុំត្រពាំងប្រាសាទ, ឃុំផ្អាវ ។ ដល់ចែកគ្នាអីចុះទៅខាងខ្ញុំនេះ ៦១២មកខាងឃុំព្រះប្រឡាយ ។ ខ្ញុំធ្វើរហូតមកទើបតែអណត្តិទី៣នេះគេឲ្យខ្ញុំសំរាក ។

ដានី: ខាងលើឲ្យអ៊ីសំរាក?

សារុន: បាទ!

ដានី: ខាងណា? ខាងខេត្ត ឬខាងស្រុក?

សារុន: ខេត្ត-ស្រុកហ្នឹងអាចគេសំរេចឲ្យខ្ញុំផ្អាក សំរាក ព្រោះតាម៉ុន គាត់ធ្វើជំទប់ខ្ញុំតាំងពីអណ្តិទី១ រហូត អីចឹងហើយបានខាងស្រុក-ខេត្ត គេថាដោះដូរគ្នាទៅ ចែកគ្នាធ្វើ អ៊ីឯងបុំន្មាន២-៣ អណត្តិហើយ ឲ្យជំទប់ទី១គាត់ឡើងធ្វើមេឃុំម្តងទៅ ។

ដានី: តែអីឥឡូវនៅជំទប់ទី១វិញ?

សារុន: ជំទប់ទី១វិញ ។

ដានី: ហើយអ៊ីម៉េចបានយើងដាក់នេះព្រះប្រឡាយ បើកាលមុនឃុំព្រះប្រឡាយយើងបង្កើតនៅ ខាងព្រះប្រឡាយនោះ ។

សារុនៈ	នៅនោះ តែទឹកដីវាជាប់ដាក់យកនាមចាស់ទៅ ។

ដានីៈ	មកដល់នេះក៏យកនាមព្រះប្រឡាយយកមកដាក់ដែរ?

សារុនៈ	បាទ! យកមកដាក់ ដូចជាភូមិព្រះប្រឡាយយកមកដាក់ដែរ ដូចជាភូមិព្រះប្រឡាយមួយ បន្ទាយចាស់ ។

ដានីៈ	ចុះភូមិព្រះប្រឡាយនៅណាទៅ?

សារុនៈ	នេះឆ្លងស្ពានមួយពីនេះទៅ ។

ដានីៈ	ម៉េចបានដាក់ឈ្មោះភូមិព្រះប្រឡាយអីចឹង? ព្រោះព្រះប្រឡាយនៅខាងព្រំដែននោះ?

សារុនៈ	ព្រះប្រឡាយតែមកនៅនេះដាក់ភូមិព្រះប្រឡាយផង ឃុំព្រះប្រឡាយផង ។

ដានីៈ	ចុះភូមិអូររំដួល ម៉េចបានដាក់ឈ្មោះភូមិអូររំដួល?

សារុនៈ	ហ្នឹងអូរជាប់សាលាឃុំគេហៅអូររំដួល ។

ដានីៈ	ដោយសារវាមានឃុំ ។ តែអ្នកណាជាអ្នកសំរេចដាក់ឈ្មោះភូមិ?

សារុនៈ	កាលនោះខ្ញុំឯង កាលហ្នឹងទៅជាមួយតាហឿន គេទៅប្រជុំជាមួយ ម៉ាត់ គេឡា នាំគ្នារក ឈ្មោះភូមិ-ឃុំដាក់ ។

ដានីៈ	ឈ្មោះត្រាំចាន?

សារុនៈ	ត្រាំចាន វាមានអន្លង់ ត្រាំចាននៅក្រោយ ពីបុរុមបុរាណគេ ។

ដានីៈ	ពីជំនាន់ណា?

សារុនៈ	មិនដឹងពីជំនាន់ណា ចាស់ទុំមកគេហៅអន្លង់ត្រាំចាន ។

ដានីៈ	មានកន្លែងគេត្រាំចានអីចឹង?

សារុនៈ	អន្លង់គេធំ អន្លង់អូរទឹកខ្លួប ។

ដានីៈ	តែកាលពីមុនគ្រាន់អត់មានមនុស្សរស់នៅ?

សារុនៈ	អត់មានទេ ។

ដានីៈ	ចុះម៉េចមានអន្លង់ត្រាំចាន?

សារុនៈ	តាំងពីដូនតាមកគេហៅអីចេះឯង ។

ដានីៈ	តែក្នុងព្រៃម៉េចមានអ្នកណាហៅអីចឹង បើអត់មានមនុស្សរស់នៅ អត់មានដឹងថាកន្លែងហ្នឹង គេហៅថាអី?

សារុនៈ	បើចាស់ទុំមុនៗ អ្នកចាងអ្នកកន្លួត មានភូមិចាកន្លួតដែលគេហៅ ។

ដានីៈ	អ្នកខាងនោះគេហៅអីចឹង?

សារុនៈ	បាទ! គេដើមចុះរកស៊ីខាងនេះ ។

ដានីៈ កន្លែងត្រាំចាន ចុះត្រាំប៉ោង?

សារុនៈ មានអូរត្រាំប៉ោងនោះមួយដែរ គេហៅអូរត្រាំប៉ោងតាំងពីដូនតាមក ។

ដានីៈ ក៏យើងដាក់អីចឹងទៅ?

សារុនៈ ដាក់ចុះទៅ ។

ដានីៈ ត្រពាំងបី, ប្រាសាទក្រហមសែនជ័យ?

សារុនៈ ប្រាសាទក្រហមសែនជ័យភូមិរបស់កងទ័ព ។

ដានីៈ ចុះត្រពាំងបី?

សារុនៈ ត្រពាំងបីប្រជាជន អត់មានកងទ័ពទេ ។

ដានីៈ ហ្នឹងទើបបង្កើតក្រោយៗទេ?

សារុនៈ ទើបបង្កើតក្រោយ មានក្រិតធ្លាក់មកពីមហាផ្ទៃទេ ។

ដានីៈ តែអីដូចជាភូមិបន្ទាយចាស់ហ្នឹងភាគច្រើន គឺវរៈណារស់នៅបន្ទាយចាស់កាលពីដំបូងមក កាលអ៊ីបង្កើត?

សារុនៈ បាទ?

ដានីៈ កាលហ្នឹងវាមានកងពល មានកងទ័ពនៅក្នុងវរៈមួយ ដល់យើងពង្រាយឲ្យរស់នៅតាមឃុំ?

សារុនៈ នេះវរៈដែលខ្ញុំប្រាប់ឲ្យទៅតាព័ន្ធ គាត់ចូលនិវត្តន៍ហើយ ។

ដានីៈ ហ្នឹងភូមិរបស់តាព័ន្ធ ។

សារុនៈ បាទ!

ដានីៈ តាព័ន្ធ ហ្នឹងគាត់វរសេនាធំ?

សារុនៈ បាទ!

ដានីៈ វរសេនាធំលេខប៉ុន្មានទៅ?

សារុនៈ មិនដឹងប៉ុន្មានទេ ។

ដានីៈ មានវរសេនាធំលេខ១៨, ១៧, ១៩?

សារុនៈ វរសេនាធំ១៨ ។

ដានីៈ ហើយព្រះប្រឡាយរបស់តាព័ន្ធដែរ?

សារុនៈ ទាំងអស់ មនុស្សភាគតិច អ្នកចាស់មានតែ៧០គ្រួសារទេពីមុនមក ។

ដានីៈ ពីមុនមកមានតែ៧០គ្រួសារទេ?

សារុនៈ បាទ! អត់ដល់១០០ផង ឥឡូវមកគ្រប់ខេត្តមកនៅនេះ ។

ដានីៈ ចុះវរៈ១៩, ១៧?

សារុនៈ មិនដឹងខាងណាខ្ញុំមិនស្គាល់ទេ ។

ដានីៈ អីចឹងក្នុងភូមិព្រះប្រឡាយភាគច្រើន១៨ទេ?

សារុនៈ ១៨ សុទ្ធតែពួក១៨ទាំងអស់ ចាស់ៗពីមុនមក តែសព្វថ្ងៃដូចជាភូមិត្រាំបៅ៉ងថ្មីសុទ្ធ សុទ្ធតែអ្នកមកពីព្រៃវែង, ស្វាយរៀង, មកពីតាកែវ កំពង់ចាម រាប់រយគ្រួសារ ។

ដានីៈ អ៊ំបង្កើតជាភូមិ-ឃុំ វត្តអ៊ីមានបានបង្កើតនៅ?

សារុនៈ វត្តបង្កើតហើយ ឥឡូវមានវត្ត៣នៅក្នុងឃុំមួយនេះ ។

ដានីៈ ក្នុងឃុំព្រះប្រឡាយនេះមានវត្ត៣?

សារុនៈ បាទ!

ដានីៈ វត្តនៅណាខ្លះទៅ?

សារុនៈ វត្តទួលប្រទមួយនៅក្នុងភូមិអូររំដួល ។ ហើយវត្តត្រាំបៅ៉ងមួយ ហើយវត្តប្រាសាទក្រហមសែនជ័យនោះមួយ ហ្នឹង៣ ។

ដានីៈ វត្ត៣កន្លែង?

សារុនៈ ៣ ។

ដានីៈ ចុះកាលពីមុនមក កាលពីជំនាន់តស៊ូមានវត្តដែរ?

សារុនៈ អត់មានទេ ។

ដានីៈ ចុះមានធ្វើបុណ្យដែលកាលជំនាន់នោះ?

សារុនៈ ធ្វើ មានអ្នកស្លាប់ក៏ចាស់ទុំ អ្នកសូត្រធម៌ អត់មានលោកទេ ចាស់ៗធ្លាប់បួសពីមុនមក ។

ដានីៈ ឥឡូវនេះយើងមានវត្ត ហើយសាសនាផ្សេងៗមានដែលអត់ទេនៅក្នុងភូមិយើង?

សារុនៈ មានខាងយេស៊ូ ។

ដានីៈ យេស៊ូ គេមានវិហារដែរ?

សារុនៈ អត់ទាន់មានទេ គេគ្រាន់តែជួយធ្វើសាលាក្មេងរៀន នៅត្រាំបៅ៉ង ។

ដានីៈ មានប្រជាជនយើងចូលខាងយេស៊ូច្រើនទេ?

សារុនៈ មានខ្លះដែរ តែមិនច្រើនប៉ុន្មានទេ ។

ដានីៈ ប្រហែលជាប៉ុន្មានភាគរយ?

សារុនៈ យ៉ាងច្រើន២០គ្រួសារ ។

ដានីៈ ហើយដូចអ៊ំជាអ្នកដឹកនាំតាំងពីយើងមិនទាន់ផ្តាច់ខ្លួន រហូតដល់ក្រោយនេះទៀត អ៊ំយល់ឃើញថាតើការរស់នៅតាំងពីយើងមិនទាន់ផ្តាច់ខ្លួន ការរស់នៅជីវភាព ទំនៀមទំលាប់ប្រពៃណី សិទ្ធិសេរីភាពពីមុន ហើយការផ្តាច់ខ្លួនហើយមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

សារុនៈ ខុសគ្នា មុនមិនទាន់ផ្ដាច់ខ្លួនមកវាយ៉ាប់យ៉េនដែរ កាលនោះកំហុសអីមិនមានគុកដាក់ទេ ។

ដានីៈ កំហុសអីយ៉ាងម៉េចទៅ?

សារុនៈ ឧបមាថាបុគ្គលណាធ្វើខុសគេយកវៃចោលកាលមិនទាន់ផ្ដាច់ខ្លួន ។

ដានីៈ កាលមិនទាន់ផ្ដាច់ខ្លួនកាលនៅលើភ្នំនៅវៃចោល?

សារុនៈ បាទ! នៅ ទើបតែចូលរដ្ឋាភិបាលទេបានមានច្បាប់ មានទម្លាប់ ធ្វើខុសគេមានគុក ពីមុនមកអត់ទេ ។

ដានីៈ ហើយការរស់នៅ ជីវភាពខុសគ្នាដែរអត់ទេ?

សារុនៈ ខុស កាលនោះវាយ៉ាប់ មានអីសុទ្ធតែបាតដៃទទេទាំងអស់គ្នា អត់មានធ្វើអីទេ ធ្វើតែចំការទេ កាប់ដាំស្រូវហូប បើធ្វើស្រែវិញកាប់ចិញ្ច្រាំនឹងចប លំបាក ។

ដានីៈ ឥឡូវនេះយើងស្រួលជាង?

សារុនៈ ឥឡូវនេះធូរធារមែនទែន យើងអត់លែងឃ្លាន កើតផ្ទះសំបែង ពីដើមបាតដៃទទេទាំងអស់គ្នា ។

ដានីៈ អ៊ំទាក់ទងនឹងក្មេងៗវិញ ដូចថាក្មេងៗកើតក្រោយៗនេះ ទើបអាយុ៤-៥ឆ្នាំ ១០ឆ្នាំ ដែលកើតក្រោយយើងផ្ដាច់ខ្លួន ដូចថាអ៊ំធ្លាប់និយាយប្រាប់ក្មួយៗ ចៅៗ ឬក៏កូនដែលកើតក្រោយៗ ធ្លាប់និយាយពីរឿងជីវិត ការរស់នៅសម័យតស៊ូ សម័យកកើតស្រុកភូមិយើង ការលំបាកលំបិន ធ្លាប់និយាយដែលអត់?

សារុនៈ ខ្ញុំធ្លាប់និយាយណែនាំកូនចៅដែលរៀនសព្វថ្ងៃនេះ កូនដែលធំក្រោយ ដំណាលកាលឪពុកម្ដាយ ចាស់ៗវេទនា ភ័យខ្លាច ការរស់នៅជាប្រចាំថ្ងៃមិនទៀងទាត់ ហើយមិនដឹងថ្ងៃណាងាប់ ថ្ងៃណារស់ វានៅមានអីចឹង យើងរស់នៅសព្វថ្ងៃនេះវាសេរីភាព យើងខំប្រឹងធ្វើការ ខំប្រឹងរៀនសូត្រឲ្យចេះដឹង ដើម្បីកុំឲ្យវាល្ងិតល្ងង់ ។ ដូចថាជំនាន់មុនសុទ្ធតែល្ងង់ហើយបានវាទៅជាអីចឹង អត់មានអ្នកចេះ ។

ដានីៈ ដូចជាខាងខ្ញុំបានសរសេរប្រវត្តិសាស្ត្រកាលពីជំនាន់៣ឆ្នាំ លើកនេះខាងខ្ញុំមានគំរោងជាមួយខាងក្រសួងទេសចរណ៍ដើម្បីសរសេរប្រវត្តិសាស្ត្រនៅតំបន់អន្លង់វែង ដូចខ្ញុំបានជំរាបប្រាប់អ៊ំ ។ សៀវភៅនេះយើងបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សា កូនសិស្សទូទាំងប្រទេសបានអានបានរៀនសូត្រពីសៀវភៅនេះហើយ គំរោងរបស់ពួកខាងខ្ញុំសរសេរសៀវភៅពីតំបន់អន្លង់វែង ត្រពាំងប្រាសាទយើងហ្នឹង គោលបំណងថាដើម្បីឲ្យក្មេងៗនៅខាងតំបន់យើង ឬខាងក្នុងបានរៀនសូត្រ បានយល់ដឹងពីប្រវត្តិសាស្ត្រ ។ ចំពោះអ៊ំវិញ អ៊ំយល់ថា អ៊ំគាំទ្រគួរតែ

បញ្ចូលផ្នែកប្រវត្តិសាស្ត្រហ្នឹងឲ្យក្មេងៗ បានរៀនសូត្រយល់ដឹងកាលពីជំនាន់យើងតស៊ូដែរ ឬយ៉ាងម៉េច?

សារុនៈ ខ្ញុំថាគួរ គួរត្រង់ថា ជំនាន់នោះរបបហ្នឹងវាយ៉ាប់យ៉ឺនណាស់ ការរស់នៅវាគ្មានសិទ្ធ គ្មានសេរីភាព ប្រៀបដូចសត្វធាតុទៅ ដូចខ្ញុំនិយាយថាអ្នកណាខុសខ្លះអត់មានគុកដាក់ទេ ចុះមកនៅដីខ្មែរក៏នៅប្រើអំពើនោះដដែល ។

ដានីៈ ពេលដែលយើងចុះមកឆ្នាំ៩០មកនៅដីខ្មែរ ក៏នៅតែមានបញ្ហាកាប់សម្លាប់អីចឹងដែរ?

សារុនៈ នៅតែមានបញ្ហា ។

ដានីៈ អ៊ំនៅភ័យខ្លាចអីចឹងដែរ?

សារុនៈ ភ័យខ្លាច ។

ដានីៈ ទោះជាអ៊ំធ្វើការជាមួយពួកគាត់ក៏នៅតែខ្លាច?

សារុនៈ ព្រោះអ្នកធ្វើការអត់ទៀងទាត់ទេ ធ្វើដូចខ្ញុំអីចឹងនៅតែភ័យ បើហៅទៅណាសុទ្ធតែគិតពិចារណាថាហៅទៅមិនដឹងងាប់ មិនដឹងរស់ នៅមានគំនិតគិតអីចឹង ។

ដានីៈ កាលអ៊ំនៅស្រុកកំណើត កាលនៅព្រះវិហារ នៅរវៀង កាលជំនាន់៣ឆ្នាំអីកាលហ្នឹងយ៉ាងម៉េចដែរ ស្ថានភាពការរស់នៅកាលជំនាន់៣ឆ្នាំ?

សារុនៈ កាលជំនាន់នោះយ៉ាប់ត្រង់ថាបញ្ហាហូបចុក សំខាន់បញ្ហាហូបចុក និងធ្វើការងារ ។

ដានីៈ មានគេចាប់ គេសម្លាប់ដែរ?

សារុនៈ មាន ។

ដានីៈ កាលហ្នឹងអ៊ំជាប្រជាជនទេ យើងអត់មានឲ្យគេគ្រប់គ្រងអីទេ?

សារុនៈ ជាប្រជាជន តែខ្លាច មិនដឹងខុសអី ។

ដានីៈ កាលហ្នឹងគណៈតំបន់ឈ្មោះអីទៅកាលនៅព្រះវិហារ?

សារុនៈ ខ ហង់ ។

ដានីៈ ម៉េចបានគេហៅ ខ ហង់ អីចឹង?

សារុនៈ មិនដឹងម៉េចទេ គេហៅអីចឹង ។

ដានីៈ ចុះនៅខាងស្រុករវៀងពីណាគេគណៈស្រុក ។

សារុនៈ ស្រុករវៀងស្លាប់អស់ហើយឥឡូវ អត់មានសល់ទេពីជំនាន់នោះអ្នកធ្វើការខ្ទិចអស់ តាំងពីភូមិ ឃុំ ។

ដានីៈ ខ្ញុំដូចជាអស់សំនួរត្រូវសួរនាំអ៊ំទៀតហើយ អ៊ំមានអីចង់បន្ថែមនៅអ្វីដែលខ្ញុំអត់បានសួរនាំអ៊ំទេ?

*សារុនៈ*		*ដូចអត់មានអីទេ ។*

*ដានីៈ*		*អីចឹងខ្ញុំអរគុណអ៊ំច្រើន  ដែលផ្តល់ពេលវេលាជិតមួយម៉ោងឲ្យខ្ញុំសាកសួរទាក់ទងពីបទពិសោធន៍របស់អ៊ំនេះ ខ្ញុំអរគុណអ៊ំច្រើន ។*

**ចប់**